Institut Pasteur du Cambodge

*រៀបរៀងដោយ វេជ្ជ.ហេង សៃណាយីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺរាគ ដែលបង្កឡើងដោយ ROTAVIRUS

## ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងប្រភេទនេះ?

រ៉ូតាវីរុស(*Rotavirus*) ជាមេរោគម្យ៉ាងដែលអាចបណ្តាលអោយកើតជំងឺរាគ ជាពិសេសចំពោះទារក និងកុមារតូចៗ។ ស្ថានភាពរាគនេះអាចធ្ងន់ធ្ងរដែលនាំអោយមានការខ្សោះជាតិទឹក។ ការក្អួត និងក្តៅខ្លួន ត្រូវបានជួបជាញឹកញាប់ផងដែរ ក្នុងករណីរាគដែលបណ្តាលមកពីរ៉ូតាវីរុសនេះ។

នៅមុនពេលដែលវ៉ាក់សាំងបង្ការរ៉ូតាវីរុសត្រូវបានបង្កើតឡើង ជំងឺរាគដែលបង្កឡើងដោយរ៉ូតាវីរុស គឺជាបញ្ហាសុខភាពដ៏ចំបងមួយ នៅសហរដ្ឋអាមេរិក។ ស្ទើរគ្រប់ក្មេងទាំងអស់ត្រូវបានឆ្លងមេរោគនេះ យ៉ាងហោចណាស់មួយដង មុនពេលពួកគេអាយុ ៥ឆ្នាំ។

វ៉ាក់សាំងបង្ការជំងឺរាគដែលបង្កឡើងដោយរ៉ូតាវីរុសត្រូវបានផលិតឡើង ក្នុងឆ្នាំ២០០៦។ ចាប់តាំងពីពេលនោះមក ដោយសារប្រសិទ្ធភាពរបស់ថ្នាំបង្ការនេះ ចំនួនកុមារដែលចូលសំរាកពេទ្យ និងចំនួនកុមារដែលត្រូវសង្គ្រោះបន្ទាន់ ដែលបណ្តាលមកពីការបង្ករោគដោយសារមេរោគនេះ មានការធ្លាក់ចុះគួរអោយកត់សំគាល់ នៅក្នុងសហរដ្ឋអាមេរិក។

## ២- វ៉ាក់សាំងបង្ការជំងឺរាគបង្កដោយ Rotavirus

វ៉ាក់សាំងនេះត្រូវផ្តល់ដល់កុមារ ចំនួន ២ដង តាមការណែនាំដូចខាងក្រោម៖

- ដូសទីមួយ: នៅពេលកុមារអាយុពី ១ខែកន្លះ ទៅ ២ខែ
- ដូសទីពីរ: ពី ១ខែ ទៅ ២ខែ បន្ទាប់ពីដូសទី១

<u>**បញ្ជាក់**</u>: ដូសទី២ ដាច់ខាតត្រូវផ្តល់អោយបានមុន កុមារអាយុ ៦ខែ។

វ៉ាក់សាំងនេះមានទំរង់ជាទឹក សំរាប់ផ្តល់តាមមាត់ មិនមែនជាទំរង់ថ្នាំចាក់ឡើយ។ ថ្នាំបង្ការជំងឺរាគនេះអាចផ្តល់ព្រមពេលជាមួយគ្នានឹងថ្នាំបង្ការផ្សេងៗទៀត។ វ៉ាក់សាំងបង្ការជំងឺរាគដែលបង្កដោយ Rotavirus នេះ មានប្រសិទ្ធភាពខ្ពស់ប្រឆាំងនឹងការរាគ រឺក្អួត ដែលបណ្តាលមកពីមេរោគនេះ។ ស្ទើរតែគ្រប់កុមារទាំងអស់ដែលបានទទួលវ៉ាក់សាំងនេះអាចជៀសផុតពីអការៈរាគធ្ងន់ធ្ងរ ដែលបណ្តាលមកពី Rotavirus។ ទោះយ៉ាងណាក៏ដោយ ថ្នាំបង្ការជំងឺរាគមិនអាចការពារការរាគ រឺក្អួត ដែលបណ្តាលមកពីមេរោគផ្សេងៗទៀតបានឡើយ។

## ៣- តើកុមារណាខ្លះដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- កុមារដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរ ជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀត ដែលមានក្នុងវ៉ាក់សាំងនេះ
- កុមារដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ
- កុមារដែលធ្លាប់មានប្រវត្តិពោះវៀនលូនចូលគ្នា
- កុមារដែលកំពុងមានជំងឺ (ការផ្តល់វ៉ាក់សាំងគួរត្រូវបានពន្យាពេលរហូតដល់កុមារជាសះស្បើយសិន)

## ៤- ផលវិបាកដែលអាចកើតមានក្រោយទទួលវ៉ាក់សាំង

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលថ្នាំបង្ការនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- រាគ រឺក្អួត ក្នុងទំរង់ស្រាល រញ៉ាំរញ៉ូវ
- ពោះវៀនលូនចូលគ្នា: វាជាទំរង់មួយនៃការស្ទះពោះវៀនស្រួចស្រាវលើកុមារ។ ក្នុងករណីនេះ កុមារត្រូវសំរាកពេទ្យជាបន្ទាន់ ហើយនិងអាចត្រូវទទួលការព្យាបាល ដោយការវះកាត់ទៀតផង ក្នុងករណីចាំបាច់។

ពោះវៀនលូនចូលគ្នាអាចកើតមានឡើងនៅសប្តាហ៍ ទី១ ក្រោយទទួលវ៉ាក់សាំងបង្ការជំងឺរាគ។ ក៏ប៉ុន្តែ ហានិភ័យនេះត្រូវបានគេប៉ាន់ប្រមាណថាអាចកើតមានក្នុងចន្លោះពី ១ ក្នុងចំណោមទារក ២ម៉ឺន នាក់ ទៅ ១១ ក្នុងចំនោមទារក ១សែននាក់ ប៉ុណ្ណោះ។

**ប្រសិនបើមានសញ្ញាប្រតកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**